គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣/៧/៩៥៤៧ក.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ សេចក្តីណែនាំក្នុងការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧។

**យោង** ៖ - សេចក្តីសម្រេចលេខ ០០១សសរ/គ.ជ.វ.វ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

- សេចក្តីជូនដំណឹងលេខ ០៤៨សជណ/គ.ជ.អ.ប ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ និង សេចក្តីជូនដំណឹងលេខ ០៧៦សជណ/គ.ជ.អ.ប ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំថ្មីបន្ថែមមួយចំនួន សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០០៩ (PIM) ជំពូក៣ ចំណុច៣.២ តម្រូវឱ្យរាជធានី ខេត្ត រៀបចំបញ្ជីឈ្មោះអ្នកទទួលការប្រចាំឆ្នាំបានចប់សព្វគ្រប់មិនឱ្យហួសពីថ្ងៃទី៣១ ខែធ្នូ។ ដំណើរការនេះ ត្រូវចាប់ផ្តើមពីការបង្កើតអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិអ្នកទទួលការ និងការប្រកាសស្តីពីការដាក់ពាក្យចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ តាមរាជធានី ខេត្តនីមួយៗ តាមទម្រង់២៣ ដែលការប្រកាសនេះ មិនត្រូវឱ្យយឺតជាងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ ឡើយ និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាពិសេសត្រូវបិទផ្សព្វផ្សាយនៅលើក្តារព័ត៌មានរបស់សាលារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។

រាជធានី ខេត្តត្រូវផ្ញើជូនលេខាធិការដ្ឋាន គ.ជ.អ.ប នូវសេចក្តីសម្រេចស្តីពីការបង្កើតអនុគណៈកម្មការ ទម្រង់២៣ ទម្រង់២៤ (សម្រាប់តែអ្នកទទួលការចាស់ដែលសុំប្តូរប្រភេទ និងអ្នកទទួលការថ្មី) ទម្រង់២៥ (១,២,៣) ទម្រង់២៦ (១,២,៣) ទម្រង់២៨ និងទម្រង់២៩ ដែលចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ ទម្រង់៣០ ទម្រង់៣១ និងទម្រង់៣២ និងកំណត់ហេតុប្រជុំរបស់អនុគណៈកម្មការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឱ្យបានមុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីលេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យ និងផ្តល់អនុលោមភាពជាមុន មុននឹងអភិបាលចុះហត្ថលេខាផ្លូវការលើបញ្ជីឈ្មោះអ្នកទទួលការរបស់រាជធានី ខេត្តសាមី។

ដើម្បីចៀសវាងបាននូវភាពមិនប្រក្រតីទាំងឡាយ ក្នុងការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ លេខាធិការដ្ឋាន គ.ជ.អ.ប ស្នើសុំអនុគណៈកម្មាធិការបុរេលក្ខណៈសម្បត្តិរាជធានី ខេត្ត យកចិត្តទុកដាក់ និងពង្រឹងនីតិវិធីរៀបចំបញ្ជីឈ្មោះអ្នកទទួលការចាប់ពីការទទួលពាក្យស្នើសុំ ក៏ដូចជាវាយតម្លៃគុណភាពគម្រោង គ្រឿងចក្រ និងបុគ្គលិកដល់ទីកន្លែង ដើម្បីធានាបាននូវភាពជាម្ចាស់ការទទួលខុសត្រូវ តម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង។

អាស្រ័យហេតុនេះ សូមឯកឧត្តមចាត់វិធានការតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយប្រសិទ្ធិភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

ជ. **ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
**អគ្គលេខាធិការរង**

**ទៀង ចំរើន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ
- ឯកសារ-កាលប្បវត្តិ